# ជំងឺរលាកសួតប្រភេទថ្មីបណ្តាលពីវីរុសកូរ៉ូណា 2019 (COVID-19)

ជំងឺរលាកសួតប្រភេទថ្មីបណ្តាលពីវីរុសកូរ៉ូណា 2019 (COVID-19)
គឺជាជំងឺវាយប្រហារផ្លូវដង្ហើមរបស់មនុស្សដោយសាវីរុសថ្មីមួយប្រភេទ ។ វាជាជំងឺដែលឆ្លងពីមនុស្សម្នាក់ទៅម្នាក់ ។

ដោយសារនេះជាវីរុសថ្មី គឺនៅមានរឿងច្រើនដែលយើងមិនទាន់អាចដឹងបាន តែយើងកំពុងតែសិក្សាពីវា (COVID-19) រៀងរាល់ថ្ងៃ ។

សហគមន៍សុខភាពសាធារណៈរបស់រដ្ឋមីណេសូតា កំពុងខិតខំយ៉ាងសស្រាក់សស្រាំ ដើម្បីពន្យឺតការរាតត្បាតមេរោគ COVID-19 នៅក្នុងរដ្ឋរបស់យើង ហើយកិច្ចការនេះ គឺមិនអាចសម្រេចទៅបានឡើយបើសិនជាមិនមានជំនួយពីអ្នកទាំងអស់គ្នា ។

ចៀសវាងការសន្និដ្ឋាន (វាយតម្លៃ) ទៅលើអ្នកដទៃថា កើតជំងឺនេះ ។ វីរុសវាយប្រហារមនុស្សគ្រប់ប្រភេទទាំងអស់ ។

## រោគសញ្ញា

អ្នកដែលបានធ្វើតេស្តឃើញថាមានមេរោគ COVID-19 នៅក្នុងខ្លួន គឺកើតជំងឺផ្លូវដង្ហើមក្នុងកម្រិតស្រាល ទៅធ្ងន់ ដោយមានរោគសញ្ញាដូចជា ៖

- គ្រុនក្តៅ
- ក្អក
- ដកដង្ហើមដង្ហក់

មនុស្សដែលឈឺក្នុងកម្រិតស្រាល ដោយមេរោគ COVID-19 ត្រូវស្នាក់នៅផ្ទះ ក្នុងពេលខ្លួនកើតជំងឺនេះ ។ បើអាចចៀសបានសូមកុំចេញក្រៅផ្ទះ លើកលែងតែករណីទៅរកពេទ្យ។សូមហៅទូរស័ព្ទទៅជួបអ្នកផ្តល់សេវាកម្មថែទាំសុខភាពរបស់អ្នក បើអ្នកត្រូវការការថែទាំវេជ្ជសាស្ត្រ ។

## ការពារខ្លួនអ្នក និងសហគមន៍អ្នក

វិធីដ៏ប្រសើរបំផុត ដើម្បីការពារខ្លួនអ្នកពីមេរោគ COVID-19 គឺត្រូវធ្វើដូចគ្នាទៅនឹងអ្វីដែលអ្នកធ្វើដើម្បីការពារខ្លួនអ្នកពីជំងឺផ្តាសាយធម្មតា និងផ្តាសាយធំ ៖

- ត្រូវលាងដៃឲ្យបានញឹកញាប់ជាមួយសាប៊ូ និងទឹក ។
- ត្រូវស្នាក់នៅផ្ទះបើអ្នកឈឺ ។
- ខ្ទប់មាត់ពេលក្អក ។
- ត្រូវសំអាត និងកំចាត់មេរោគចំពោះរបស់ និងផ្ទៃរបស់ផ្សេងៗដែលអ្នកប៉ះពាល់ញឹកញាប់ ។

ត្រូវប្រុងប្រយ័ត្នអំពីប្រភពព័ត៌មានដែលអ្នកទទួលបានអំពីជំងឺ COVID-19 ។ ការសន្យា ឬការធានាថាគេអាចព្យាបាលជំងឺ COVID-19 “ជាសះស្បើយ” គឺជាព័ត៌មានដែលមិនត្រឹមត្រូវ ។ គិតមកដល់ពេលនេះ គឺនៅមិនទាន់មានវ៉ាក់សាំងការពារមេរោគ COVID-19 នៅឡើយទេ។ សូមបន្តអានព័ត៌មានក្នុងវិបសៃត៍របស់ MDH និង CDC សម្រាប់ព័ត៌មាន អំពីរបៀបជួយបង្ការមេរោគ COVID-19 ។

## ព័ត៌មានបន្ថែម

ទទួលបានព័ត៌មានថ្មីៗបំផុតអំពីមេរោគ COVID-19 ពីវិបសៃត៍ទាំងអស់នេះ ។

- នាយកដ្ឋានសុខាភិបាលមិណេសូតា (Minnesota Department of Health) ព័ត៌មានអំពីវីរុសកូរ៉ូណា 2019 (COVID-19) (www.health.state.mn.us/diseases/coronavirus/index.html) ។
- មជ្ឈមណ្ឌលគ្រប់គ្រង និងបង្ការជំងឺ (Centers for Disease Control and Prevention) ព័ត៌មានអំពីវីរុសកូរ៉ូណា 2019 (www.cdc.gov/coronavirus/2019-ncov/index.html) ។